**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ
ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី
ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១១

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 14-Oct-2011, 13:41
CMS/CFO: Kauv Keoratanak

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**
ចំណាត់ថ្នាក់ប្រភេទឯកសារ
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

**ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញទៅលើ "ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ ស្ទួនពីរនៃវិធានផ្ទៃក្នុង"**

---

**ដាក់ដោយ:**

**សហមេធាវី:**

អាង ឧត្តម
Michael G. KARNAVAS

**អង្គជំនុំជម្រះសាលាដំបូង:**

ចៅក្រម **និល ណុន** ប្រធាន
ចៅក្រម **យ៉ូរ ឧត្តរា**
ចៅក្រម **យ៉ា សុខន**
ចៅក្រម Silvia CARTWRIGHT
ចៅក្រម Jean-Marc LAVERGNE
ចៅក្រមបម្រុង **ធូ មណី**

ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា៖**

ជា លាង

Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក អៀង សារី តាមរយៈសហមេធាវីរបស់ខ្លួន ("មេធាវីការពារក្តី") សូមដាក់ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការពិចារណាឡើងវិញទៅលើ "ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីដោយអនុលោមតាមវិធាន ៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង" ("សំណើ")[1]។ មេធាវីការពារក្តីសូមអះអាងថា៖ **ក.** អង្គជំនុំជម្រះសាលាដំបូងអាចពិចារណាឡើងវិញបានទៅលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ប៉ុន្តែសូមប្រកាន់ជំហរអព្យាក្រឹតត្រង់ចំណុចថាតើ ក.ស.ព បានបញ្ជាក់គ្រប់គ្រាន់ហើយឬនៅអំពី "មូលដ្ឋានគតិយុត្តិត្រឹមត្រូវ" ដែលតម្រូវឲ្យអង្គជំនុំជម្រះត្រូវពិចារណាឡើងវិញទៅលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ដោយអនុលោមតាមវិធាន ៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង (ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី)[2] **ខ.** ការបំបែកកិច្ចដំណើរការនីតិវិធីត្រូវស្របតាមវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ("វិធាន") ពោលគឺ ស្របទៅតាមបទចោទ **គ.** អង្គជំនុំជម្រះពុំអាចអនុវត្តតាមគំរូណែនាំស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីរបស់តុលាការ ICTY បានឡើយ **ឃ.** ការចោទជាសំណួររបស់ ក.ស.ព ទៅលើភាពត្រឹមត្រូវនៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ដែលថានឹងមានការជំនុំជម្រះនៅដំណាក់កាលបន្ទាប់ទៀតក្នុងសំណុំរឿង០០២ គឺជាការពុំត្រឹមត្រូវ **ង.** ក.ស.ព ពុំបានបង្ហាញថា ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ពុំមែនធ្វើឡើងដើម្បីជាផលប្រយោជន៍នៃយុត្តិធម៌ឡើយ និង **ច.** សំណើសុំផ្សេងទៀតក្នុងការបំបែកកិច្ចដំណើរការនីតិវិធីរបស់ ក.ស.ព នឹងពុំធ្វើឲ្យការជំនុំជម្រះប្រព្រឹត្តទៅបានឆាប់រហ័សដូចការអះអាងរបស់ ក.ស.ព ឡើយ ថ្វីបីមេធាវីការពារក្តីយល់ថា សំណើនេះធ្វើឡើងដោយអនុលោមតាមវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង អ.វ.ត.ក ក្តី ("វិធាន") ក៏ដោយ។ មេធាវីការពារក្តីស្នើសុំឲ្យមានសវនាការផ្ទាល់មាត់ជាសាធារណៈ។

## I. ប្រវត្តិ

### ក. ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី

១. ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី រៀបរាប់អំពីប្រធានបទដែលត្រូវជំនុំជម្រះនៅដំណាក់កាលដំបូងនៃសវនាការលើសំណុំរឿង ០០២ ដូចខាងក្រោម៖

[1] សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញទៅលើ "ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិ វិធីអនុលោមតាមវិធាន ៨៩*ស្ទួនពីរ*នៃវិធានផ្ទៃក្នុង" ចុះថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០១១, ឯកសារលេខ E124/2។

[2] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីអនុលោមតាមវិធាន ៨៩*ស្ទួនពីរ*នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១, លេខឯកសារ E124។

ក) រចនាសម្ព័ន្ធរបបកម្ពុជាប្រជាធិបតេយ្យ

ខ) តួនាទីរបស់ជនជាប់ចោទម្នាក់ៗ នៅមុនពេលមានការបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ និងនៅពេលជនជាប់ចោទម្នាក់ៗបានទទួលការចាត់តាំងនូវតួនាទីទាំងនេះ

គ) តួនាទីរបស់ជនជាប់ចោទម្នាក់ៗក្នុងជួររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ការទទួលខុសត្រូវរបស់ពួកគេតាមការចាត់តាំង ក្របខណ្ឌនៃសិទ្ធិអំណាចរបស់ពួកគេ និងខ្សែបណ្តាញទាក់ទងនៅក្នុងរយៈកាល ដែលពាក់ព័ន្ធនឹងយុត្តាធិការតាមពេលវេលារបស់ អ.វ.ត.ក

ឃ) គោលនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យស្តីពីបញ្ហាទាំងឡាយ ដែលបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ

...

[(ង)] ការចោទប្រកាន់លើអង្គហេតុ ដែលមានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជននៅក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២ និង

[(ច)] ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ រួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ (លើកលែងតែការធ្វើទុក្ខបុកម្នេញដោយហេតុផលសាសនា) ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ (ដោយហេតុថាអង្គហេតុទាំងនេះពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជននៅក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២)[3]។

២. បទចោទប្រកាន់មួយចំនួនត្រូវបានដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី បំបែកចេញពីដីកាដំណោះស្រាយ ដែលរួមមាន បទមនុស្សឃាត, ការសម្លាប់រង្គាល, ការធ្វើទុក្ខបុកម្នេញ (លើកលែងតែការធ្វើទុក្ខបុកម្នេញដោយហេតុផលសាសនា), ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២។ បទចោទប្រកាន់ដទៃទៀតដែលនៅសេសសល់ក្នុងដីកាដំណោះស្រាយ

[3] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ១, ៥។

នឹងត្រូវជំនុំជម្រះនៅដំណាក់កាលក្រោយទៀត។

## ខ. សេចក្ដីសង្ខេបនៃសំណើរបស់ ក.ស.ព

៣. នៅក្នុងសំណើរបស់ខ្លួន ក.ស.ព បាន៖

ក. អះអាងថា អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិក្នុងការពិចារណាឡើងវិញទៅលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី[4]

ខ. ស្នើសុំបំបែកកិច្ចដំណើរការនីតិវិធីដោយយោងទៅតាមទីកន្លែងឧក្រិដ្ឋកម្ម និងហេតុការណ៍ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ[5]

គ. យកនីតិវិធីរបស់តុលាការ ICTY[6], វិធាន ៧៣*ស្ទួន* នៃវិធាននីតិវិធី និងភស្តុតាងរបស់តុលាការ ICTY ("វិធាន ៧៣*ស្ទួន* របស់តុលាការ ICTY")[7] និងយុត្តិសាស្ត្រតុលាការ ICTY[8] មកធ្វើជាសំអាង

ឃ. អះអាងថាទំនងជាពុំមានការជំនុំជម្រះនៅដំណាក់កាលក្រោយទៀតក្នុងសំណុំរឿង ០០២ ទេ[9]

ង. អះអាងថា ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីដែលអង្គជំនុំជម្រះបានចេញ

---

[4] សំណើ, កថាខណ្ឌ ៧-១៦។

[5] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ៣៦។

[6] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ២០។

[7] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ២១។

[8] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ២២-២៣។

[9] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ៣ ("បទចោទសម្រាប់ជំនុំជម្រះជនជាប់ចោទនៅដំណាក់កាលដំបូង ហើយក៏ជាសវនាការដំណាក់កាលចុងក្រោយផងដែរ..."), កថាខណ្ឌ ១៥ ("នេះជាការពិត បើយើងយោងតាមលទ្ធភាពជាក់ស្ដែងដែលពុំអាចមានការជំនុំជម្រះដំណាក់កាលបន្ទាប់ទៀត"), កថាខណ្ឌ ២៤ ("ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីប្រមើលឃើញថាជនជាប់ចោទអាចនឹងប្រឈមមុខនឹងការជំនុំជម្រះច្រើន។ ប្រការនេះទំនងជាពុំអាចកើតឡើងបានឡើយ), កថាខណ្ឌ ២៩ ("ដោយយោងទៅលើហានិភ័យនេះដែលធ្វើឱ្យ អ.វ.ត.ក ជំនុំជម្រះជនជាប់ចោទបានត្រឹមតែមួយដំណាក់កាល...)។

គឺពុំមែនដើម្បីជាផលប្រយោជន៍នៃយុត្តិធម៌ឡើយ[10] និង

ច. អះអាងថា "ការដាក់បញ្ចូលនូវ...ទីតាំងឧក្រិដ្ឋកម្មបន្ថែមទៀត នឹងពុំធ្វើឲ្យការជំនុំជម្រះដំណាក់កាលដំបូង អូសបន្លាយពេលយូរឡើយ"[11]

## II. ចម្លើយតប

### ក. អង្គជំនុំជម្រះសាលាដំបូងអាចពិចារណាឡើងវិញបានទៅលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់ខ្លួន

៤. ក.ស.ព អះអាងថា អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិដើម្បីពិចារណាឡើងវិញទៅលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីដែលខ្លួនបានចេញនេះ[12]។ អង្គបុរេជំនុំជម្រះបានលើកឡើងថា ភាគីគួរមានសិទ្ធិក្នុងការស្នើសុំឲ្យមានការពិចារណាឡើងវិញ នៅពេលខ្លួនមាន "មូលដ្ឋានគតិយុត្តិត្រឹមត្រូវ"[13]។ នៅក្នុងករណីបច្ចុប្បន្ននេះ គ្មានអ្វីរាំងមិនឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញទៅលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនេះឡើយ។ មេធាវីការពារក្តីសូមប្រកាន់ជំហរអព្យាក្រឹតពាក់ព័ន្ធនឹងបញ្ហាថា តើពិតជាមានមូលដ្ឋានគតិយុត្តិត្រឹមត្រូវក្នុងការស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការពិចារណាឡើងវិញដែរឬយ៉ាងណានោះ។ ប៉ុន្តែមេធាវីការពារក្តីឯកភាពទៅនឹងទស្សនៈរបស់ ក.ស.ព ដែលថា អង្គជំនុំជម្រះសាលាដំបូងនឹងអាចទទួលបានផលប្រយោជន៍ពីយោបល់របស់ភាគីនៅមុនពេលសម្រេចលើលក្ខណៈ និងវិសាលភាពនៃការបំបែកកិច្ចដំណើរការនីតិវិធីណាមួយនៃសំណុំរឿង០០២ ដោយសារបញ្ហាទាំងអស់ដែលជាប់ពាក់ព័ន្ធសុទ្ធតែមានសារៈសំខាន់។

### ខ. ការបំបែកកិច្ចដំណើរការនិតិវិធីត្រូវស្របតាមវិធាន ៨៩*ស្ទួនពីរ* ពោលគឺស្របតាមបទចោទ

[10] *ដូចដើងទំព័រខាងលើ*, កថាខណ្ឌ ៣, *សូមមើលផងដែរ* កថាខណ្ឌ ២៤-៣៥។

[11] *ដូចដើងទំព័រខាងលើ*, កថាខណ្ឌ ៣៧។

[12] *ដូចដើងទំព័រខាងលើ*, កថាខណ្ឌ ៧-១៦។

[13] សេចក្តីសម្រេចទទួលយកសេចក្តីសង្កេតជាទូទៅរបស់ដើមបណ្តឹងរដ្ឋប្បវេណី, ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៨, ឯកសារលេខ C22/I/41, កថាខណ្ឌ ២៥, សំណើ, កថាខណ្ឌ ៨។

៥. ក.ស.ព បានសុំឲ្យអង្គជំនុំជម្រះបំបែកកិច្ចដំណើរការនីតិវិធីដោយយោងទៅតាមទីតាំងឧក្រិដ្ឋកម្ម និងហេតុការណ៍[14]។ វិធាន ៨៩ *ស្ទួនពីរ* ចែងច្បាស់ថា ការបំបែកកិច្ចដំណើរការនីតិវិធីត្រូវធ្វើដោយយោងទៅតាមបទចោទ[15]។ អង្គជំនុំជម្រះសាលាដំបូងបានបំបែកដីកាដំណោះស្រាយដោយយោងទៅតាមបទចោទ។ ដូច្នេះ ដីកានេះគឺស្របតាមគោលបំណងនៃកិច្ចប្រជុំពេញអង្គ[16] នៅពេលកិច្ចប្រជុំពេញអង្គបានធ្វើវិសោធនកម្មលើវិធានផ្ទៃក្នុង ដើម្បីបើកផ្លូវឲ្យមានការបំបែកបទចោទប្រកាន់ដែលមានក្នុងសំណុំរឿង[17]។

៦. នៅក្នុងសំណើមួយផ្សេងទៀតរបស់ខ្លួន ក.ស.ព ពុំបានស្នើសុំឲ្យអង្គជំនុំជម្រះបំបែកកិច្ចដំណើរការនីតិវិធីដោយយោងទៅតាមបទចោទឡើយ[18]។ តាមរយៈសំណើសុំបំបែកកិច្ចដំណើរការនីតិវិធីមួយផ្សេងទៀត ក.ស.ព បានស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងអនុវត្តហួសពីសមត្ថកិច្ចយុត្តាធិការ (*ultra vires*) របស់ខ្លួន។ ក.ស.ព បានស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងកែប្រែដីកាដំណោះស្រាយដោយធ្វើការកាត់បន្ថយវិសាលភាពនៃដីកាដំណោះស្រាយ[19]។ ប៉ុន្តែ វិធានផ្ទៃក្នុងពុំអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើដូច្នោះឡើយ[20]។ កន្លងមក ក.ស.ព ធ្លាប់បានឯកភាពទៅនឹងទស្សនៈ

---

[14] សំណើ, កថាខណ្ឌ ៣៦។ ផ្ទុយពីវិធានផ្ទៃក្នុង ដើមបណ្តឹងរដ្ឋប្បវេណីក៏បានយល់ឃើញដែរថា "... ប្រសិនបើមានការបំបែកកិច្ចដំណើរការនីតិវិធី គួរធ្វើទៅលើត្រឹមតែអង្គហេតុបានហើយ"។ ការជូនដំណឹងអំពីសំណើរបស់សហមេធាវីនាំមុខស្នើសុំពិចារណាឡើងវិញចំពោះការសម្រេចនៅក្នុងដីកាបំបែកនីតិវិធី អនុលោមតាមវិធាន ៨៩*ស្ទួនពីរ*, ចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១១, ឯកសារលេខ E124/4, កថាខណ្ឌ ៦(ឃ)។

[15] វិធាន ៨៩*ស្ទួនពីរ* ចែងថា "នៅពេលប្រយោជន៍យុត្តិធម៌តម្រូវ នៅដំណាក់កាលណាមួយ អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឲ្យបំបែកកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងជនជាប់ចោទមួយរូប ឬ ច្រើនរូប និងផ្នែកដែលពាក់ព័ន្ធ**<u>នឹងបទចោទខ្លះ</u>** ឬ ទាំងអស់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ រឿងក្តីដែលត្រូវបានបំបែកត្រូវយកមកជំនុំជម្រះ និងវិនិច្ឆ័យចេញសាលក្រមទៅតាមលំដាប់លំដោយដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាសមស្រប" (គូសបញ្ជាក់បន្ថែម)។

[16] នៅថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ ចៅក្រម អ.វ.ត.ក នៅក្នុងកិច្ចប្រជុំពេញអង្គលើកទី ៧ បានបោះឆ្នោតគាំទ្រការធ្វើវិសោធនកម្មវិធានផ្ទៃក្នុង ដោយដាក់បញ្ចូលបន្ថែមទៅក្នុងវិធានផ្ទៃក្នុងនូវវិធាន ៨៩*ស្ទួនពីរ* ។

[17] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ៥។

[18] ក.ស.ព ទទួលស្គាល់ថា ការបំបែកកិច្ចដំណើរការនីតិវិធី ត្រូវតែធ្វើឡើងដោយយោងទៅតាមបទចោទ, សំណើ, កថាខណ្ឌ ១៧។

[19] សំណើ, កថាខណ្ឌ ៣, ១៥, ២៤, ២៩។

[20] អង្គជំនុំជម្រះសាលាដំបូងមានសម្រេចថា "សំណើសុំលុប ឬកែប្រែផ្នែកខ្លះនៃដីកាដំណោះស្រាយ មិនមានចែងជាទូទៅនៅក្នុងក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ទេ"។ សេចក្តីសម្រេចលើអញ្ញត្រកម្មនានារបស់មេធាវីការពារក្តី (អាជ្ញាយុកាលនៃបទឧក្រិដ្ឋ

ដែលថា "វិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក មិនអនុញ្ញាតឲ្យមានញត្តិស្នើសុំលុបចោល ឬធ្វើវិសោធនកម្មលើផ្នែកខ្លះនៃដីកាដំណោះស្រាយនៅពេលដែលដីកានេះចូលជាស្ថាពរហើយនោះទេ"[21]។

**គ. អង្គជំនុំជម្រះសាលាដំបូងពុំអាចទទួលយកការណែនាំស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីរបស់តុលាការ ICTY បានឡើយ**

**i. នីតិវិធីរបស់តុលាការ ICTY ពុំសមស្របក្នុងការណែនាំដល់អង្គជំនុំជម្រះសាលាដំបូងឡើយ**

៧. ក.ស.ព បានសំអាងទៅលើនីតិវិធីតុលាការ ICTY ដោយអះអាងថា អង្គជំនុំជម្រះសាលាដំបូងគួរទទួលយកការណែនាំពីវិធាន ៧៣*ស្ទួន* របស់តុលាការ ICTY[22]។ ប៉ុន្តែ នីតិវិធីតុលាការ ICTY ក្នុងការកាត់បន្ថយវិសាលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺពុំស្របទៅនឹងនីតិវិធី អ.វ.ត.ក ស្តីពីការបំបែកដីកាដំណោះស្រាយឡើយ។

៨. នៅតុលាការ ICTY ដែលជាតុលាការប្រើប្រាស់ប្រព័ន្ធច្បាប់ខមិនឡូដឹកនាំដោយគូភាគី ភាគីអយ្យការជាអ្នកតាក់តែងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[23]។ នៅពេលអង្គជំនុំជម្រះសាលាដំបូងស្នើសុំឲ្យមានការបំបែកដីកាបញ្ជូនរឿងទៅជំនុំជម្រះ ភាគីអយ្យការជាអ្នកទទួលបន្ទុកកិច្ចការនេះ[24]។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះអាចត្រូវបានកាត់ចោលផ្នែកខ្លះអាស្រ័យទៅតាម "ចំនួននៃបទចោទដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ឬ "ទីតាំងឧក្រិដ្ឋកម្ម ឬហេតុការណ៍ដែលស្ថិតនៅក្នុងបទចោទមួយ ឬច្រើន"[25]។ ជារួម ក្នុងអំឡុងដំណាក់កាលជំនុំជម្រះ ភាគីអយ្យការជាអ្នកមានសិទ្ធិសម្រេចលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

---

តាមច្បាប់ជាតិ), ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១, ឯកសារលេខ E122, កថាខណ្ឌ ១៦។ បទល្មើសក្រោមច្បាប់ជាតិត្រូវបានលុបចេញពីដីកាដំណោះស្រាយ ដោយសារពុំស្របទៅនឹងស្មារតីនៃវិធាន ៦៧(២)។

[21] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹង "ញត្តិរបស់ អៀង សារី ស្នើសុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយដោយសារកំហុសផ្នែកនីតិវិធី", ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ E58/1, កថាខណ្ឌ ៣។

[22] សំណើ, កថាខណ្ឌ ១៧, ២០។

[23] វិធាននីតិវិធី និងភស្តុតាងនៃតុលាការ ICTY, វិធាន ៤៧។

[24] វិធាន ៧៣*ស្ទួន* នៃតុលាការ ICTY។

[25] *ដូចជើងទំព័រខាងលើ*។

៩. អ.វ.ត.ក ប្រើប្រាស់ប្រព័ន្ធច្បាប់ស៊ីវិលឡ[26]។ សហព្រះរាជអាជ្ញាជាអ្នកតាក់តែងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[27]។ សហចៅក្រមស៊ើបអង្កេតជាអ្នកបើកកិច្ចស៊ើបសួរដោយអនុលោមតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ បន្ទាប់មកទៀត សហចៅក្រមស៊ើបអង្កេតនឹងចេញដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឬ ដីកាលើកលែងការចោទប្រកាន់[28]។ អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿងនេះ នៅពេលខ្លួនបានទទួលដីកាដំណោះស្រាយ[29]។ វិធានផ្ទៃក្នុងពុំបានអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូង ឬភាគីណា មានសិទ្ធិកាត់ដីកាដំណោះស្រាយ ឬធ្វើវិសោធនកម្មលើដីកាដំណោះស្រាយឡើយ។ យ៉ាងណាក៏ដោយ វិធានផ្ទៃក្នុងអនុញ្ញាតឲ្យបំបែកដីកាដំណោះស្រាយជាផ្នែកតូចៗបាន[30]។ មានតែអង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះដែលមានសិទ្ធិបំបែកដីកាដំណោះស្រាយបាន[31]។ អង្គជំនុំជម្រះសាលាដំបូងអាចបំបែកដីកាដំណោះស្រាយដោយយោងទៅតាមបទចោទតែប៉ុណ្ណោះ[32]។ ការអនុវត្តនេះស្របតាមប្រព័ន្ធច្បាប់ស៊ីវិល ដោយហេតុថានៅអំឡុងដំណាក់កាលសវនាការ អង្គជំនុំជម្រះសាលាដំបូងមានតួនាទីបញ្ជាក់ការពិត[33]។

---

[26] នៅពេលគេមើលឃើញថាអង្គហេតុមួយមានភាពងាយស្រួលនោះ ក.ស.ព បែរជាមានការរារែកចិត្តមិនចង់យកអង្គហេតុនេះមកសំអាងវិញពោលគឺ៖ "យើងនៅតែអនុវត្តប្រព័ន្ធច្បាប់ស៊ីវិល ..." សំដីរបស់សហព្រះរាជអាជ្ញារងអន្តរជាតិ Bill Smith, ប្រតិចារឹក, កិច្ចប្រជុំរៀបចំសវនាការ, ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១, ឯកសារលេខ E1/2.1, ទំព័រ ៨៥។ "នីតិវិធីនៃប្រព័ន្ធច្បាប់ស៊ីវិលជាធរមាននៅចំពោះមុខ អ.វ.ត.ក ..." សំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំសេចក្តីណែនាំទាក់ទងនឹងចេតនារបស់ជនជាប់ចោទពាក់ព័ន្ធនឹងការផ្តល់សក្ខីកម្ម, ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១, ឯកសារលេខ E101, កថាខណ្ឌ ២។ ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងញត្តិរបស់ អៀង សារី សុំឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការជំនុំជម្រះលើសំណុំរឿង ០០២ ទៅតាមវិសោធនកម្មនីតិវិធីដែលបានស្នើឡើង និងសំណើសុំផ្អាកជាបន្ទាន់ដីការបង្គាប់ឲ្យដាក់សម្ភារៈ សម្រាប់ត្រៀមរៀបចំសវនាការ, ចុះថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០១១, ឯកសារលេខ E9/3/1, កថាខណ្ឌ ២(គ)។

[27] វិធាន ៥៣។

[28] វិធាន ៦៧(១)។

[29] វិធាន ៧៩(១)។

[30] វិធាន ៨៩*ស្ទួនពីរ*។

[31] *ដូចជើងទំព័រខាងលើ*។

[32] *ដូចជើងទំព័រខាងលើ*។

[33] ការិយាល័យសហព្រះរាជអាជ្ញាយល់ស្របថាតួនាទីរបស់អង្គជំនុំជម្រះសាលាដំបូងគឺដើម្បីស្វែងរកការពិត។ "ប្រការដែលថាចៅក្រមដើរតួនាទីយ៉ាងសកម្មនៅពេលដំណាលគ្នាក្នុងអំឡុងពេលដំណើការនីតិវិធីដើម្បីស្វែងរកការពិត មិនផ្លាស់ប្តូរបន្ទុកភស្តុតាងនោះឡើយ"។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅកាន់ញ្ញាតិរបស់លោក អៀង សារី ស្នើសុំឲ្យអង្គជំនុំជម្រះសាលា

អង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិសម្រេចលើដីកាដំណោះស្រាយ និងការបង្ហាញភស្តុតាង[34]។

១០. ជាងនេះទៅទៀត អង្គជំនុំជម្រះសាលាដំបូងពុំអាចទទួលយកការណែនាំពីវិធាន ៧២(ក)(iii) នៃវិធាននីតិវិធី និងភស្តុតាងរបស់តុលាការ ICTY បានឡើយ ("វិធាន ៧២(ក)(iii) របស់តុលាការ ICTY")។ វិធាន ៧២(ក)(iii) របស់តុលាការ ICTY អនុញ្ញាតឲ្យភាគីស្នើសុំបំបែកបទចោទនានានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[35]។ វិធាន ៧២(ក)(iii) អនុញ្ញាតឲ្យមានការបំបែកបទចោទ

---

ដំបូងធ្វើការជំនុំជម្រះលើករណី០០២ ដោយអនុវត្តតាមនីតិវិធី និងសំណើដែលបានលើកឡើងនិងបានកែសម្រួលសុំផ្អាកជាបន្ទាន់នូវដីកាសម្រេចដាក់ឯកសារត្រៀមរៀបចំការ ជំនុំជម្រះ, ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១១, ឯកសារ E9/3/1, ត្រង់កថាខណ្ឌទី១១ (គ), ដកស្រង់ H.D. BOSLY & D. VANDERMEERSCH, DROIT DE LA PROCEDURE PENALE, 916 (LA CHARTE, 2001): "ផ្ទុយនឹងនីតិវិធីរបស់អង់គ្លេសដែលក្នុងនោះចៅក្រមដើរតួនាទីជាអាជ្ញាកណ្តាលប៉ុណ្ណោះក្នុងអំឡុងពេលសវនាការ, អនុលោមតាមច្បាប់របស់បែលហ្ស៊ិក ចៅក្រមត្រូវចូលរួមយ៉ាងសកម្មដើម្បីស្វែងរកការពិត"។(បកប្រែក្រៅផ្លូវការ)។ *សូមមើល ឧ.*វិធាន៥៥(៥)៖ "ក្នុងការដឹកនាំកិច្ចស៊ើបសួរសហចៅក្រមស៊ើបអង្កេតអាចចាត់វិធានការស៊ើបសួរដែលនាំរកការបង្ហាញការពិត"។ វិធាន៨៥(១)៖ "ដោយមានការពិគ្រោះយោបល់ជាមួយចៅក្រមផ្សេងទៀត ប្រធានសវនាការអាចបដិសេធនូវរាល់នីតិវិធីដែលនាំឲ្យមានការពន្យារពេលដល់ការជំនុំជម្រះ និងដែលមិនអាចនាំទៅដល់ការស្វែងរកការពិត"។ វិធាន៨៧(៤)៖ " ក្នុងកំឡុងពេលសវនាការតាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះ ឬ តាមការស្នើសុំរបស់ភាគី អង្គជំនុំជម្រះអាចកោះហៅឬស្តាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬទទួលយកនូវភស្តុតាងថ្មី ដែលមានប្រយោជន៏សម្រាប់នាំមកនូវការស្វែងរកការពិត។" វិធាន៩១(៣)៖ " សហព្រះរាជអាជ្ញាភាគីទាំងអស់ និង មេធាវីអាចជំទាស់ទៅនឹងការស្តាប់ចម្លើយសាក្សី ដែលកំពុងដំណើរការប្រសិនបើខ្លួនយល់ថាចម្លើយរបស់សាក្សីនោះមិនសម្តែងឲ្យឃើញការពិត "។

[34] សហព្រះរាជអាជ្ញារងអន្តរជាតិ Bill Smith បានធ្វើការសង្កេតថា៖ "ដូចលើកលោកស្រីចៅក្រមជ្រាបស្រាប់ហើយ ហើយដូចដែលមេធាវីការពារក្តី អៀង សារី ដឹងស្រាប់ហើយគឺថា រឿងក្តីក្នុងប្រព័ន្ធច្បាប់ស៊ីវិលមិនត្រូវបានបំបែក គឺបែងចែករវាងរឿងក្តីដាក់ បន្ទុក និងរឿងក្តីដោះបន្ទុក ... យើងកំពុងដំណើរការការងារនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល មិនមែននៅក្នុងប្រព័ន្ធខំមិនឡូ ដូចនៅតុលាការប្រទេសរ៉ូវ៉ាន់ដា និងយូហ្គោស្លាវីទេ"។ ប្រតិចារឹក, កិច្ចប្រជុំរៀបចំសវនាការ, ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១, ឯកសារលេខ E1/2.1, ទំព័រ ១១៤។

[35] វិធាន៧២ (ក) (៣) របស់ ICTY ថ្លែងថា "សំណើដំបូង ដែលជាសំណើ...ស្នើឲ្យបំបែកបទចោទដែលបានដាក់បញ្ចូលគ្នាក្នុងដីកាបញ្ជូនរឿងឲ្យទៅជំនុំជម្រះមួយ អនុលោមតាមវិធាន ៤៩ ឬស្នើឲ្យកាត់ក្តីដោយឡែក ដោយអនុលោមតាមវិធាន ៨២ (២) ... ត្រូវដាក់ជាលាយលក្ខណ៍អក្សរ និងដាក់មិនឲ្យហួសពីរយៈពេល៣០ថ្ងៃ បន្ទាប់ពីរដ្ឋអាជ្ញាផ្តល់ឯកសារ និងសេចក្តីបញ្ជាក់ទាំងឡាយដល់មេធាវីការពារក្តី យោងតាមវិធាន ៦៦ (ក) (១) និងត្រូវដោះស្រាយមិនឲ្យហួសពីរយៈពេល៦០ថ្ងៃ បន្ទាប់ពីបានដាក់ឯកសារ និងមុនពេលបើកសវនាការ អនុលោមតាមវិធាន ៨៤"។ វិធាន ៤៩ នៃវិធាននីតិវិធី និងភស្តុតាងរបស់ ICTY ដែលមានចំណងជើងបទឧក្រិដ្ឋរួមចែងថា "បទឧក្រិដ្ឋពីរឬច្រើនអាចផ្តន្ទាទោសរួមគ្នាក្នុងដីកាចោទប្រកាន់តែមួយ ប្រសិនបើបទល្មើសនោះប្រព្រឹត្តជាបន្តបន្ទាប់ក្នុងសំណុំរឿងតែមួយ ហើយបង្កឡើយដោយជនជាប់ចោទតែមួយ"។

ដែលស្ថិតនៅដាច់ដោយឡែកពីគ្នា ឲ្យស្ថិតនៅជាចង្កោម ជាក់ស្តែងដូចក្នុងសំណុំរឿង Mladic[36]។ ក្នុងសំណុំរឿងនេះ ភាគីអយ្យការបានស្នើសុំបំបែកដីកាបញ្ជូនរឿងទៅជំនុំជម្រះរួមមួយ ដែលជាដីកាបញ្ជូនរឿងទៅជំនុំជម្រះចំនួន២រួមបញ្ចូលគ្នា។ ដីកាទី១ពាក់ព័ន្ធនឹង Srebrenica និងដីកាទី២ពាក់ព័ន្ធនឹងទីក្រុង Sarajevo, មន្ត្រីក្រុង និងចំណាប់ខ្មាំង (*Sarajevo, Municipalities and Hostages*)[37]។ ភាគីអយ្យការបានស្នើបំបែកដីការួមនោះ ជា២ផ្នែកដាច់ដោយឡែកពីគ្នា ដោយសំអាងមួយចំនួន ក្នុងនោះមាន (*inter alia*) សំណុំរឿងត្រូវបំបែកដោយយោងទៅតាមបណ្តុំនៃហេតុការណ៍ និងសហឧក្រិដ្ឋកម្មរួមចំនួន២ ខុសៗគ្នា[38]។

១១. អង្គជំនុំជម្រះសាលាដំបូងពុំអាចទទួលយកការណែនាំពីវិធាន ៧២(ក)(iii) ពីតុលាការ ICTY ឬសំណុំរឿង *Mladic* បានឡើយ ដោយសារហេតុផលទីមួយ គឺសំណុំរឿង០០២ ពុំមានបទចោទដាច់ដោយឡែកពីគ្នាឡើយ ពោលគឺមានតែដីកាដំណោះស្រាយមួយប៉ុណ្ណោះ។ ហេតុផលទីពីរគឺ សំណុំរឿង០០២ ពុំមានសហឧក្រិដ្ឋកម្មរួមដែលត្រូវចោទប្រកាន់ដាច់ដោយឡែកពីគ្នាឡើយ។ នៅក្នុងសំណុំរឿង ០០២ មានការចោទប្រកាន់អំពីសហឧក្រិដ្ឋកម្មរួមដ៏ធំមួយ។ ក៏ប៉ុន្តែ ការបំបែកដីកាដំណោះស្រាយដែល ក.ស.ព បានស្នើឡើង ពុំបានបញ្ជាក់បង្ហាញអំពីបណ្តុំនៃហេតុការណ៍ខុសៗគ្នាដូចដែលភាគីអយ្យការបានធ្វើនៅក្នុងសំណុំរឿង *Mladic* ឡើយ។

១២. ចំណុចខុសគ្នាខ្លាំងរវាងនីតិវិធីតុលាការ ICTY និង អ.វ.ត.ក ឬលក្ខណៈមិនសមស្របនៃនីតិវិធីតុលាការ ICTY មានន័យថា អង្គជំនុំជម្រះសាលាដំបូងពុំអាចយកនីតិវិធីតុលាការ ICTY មកអនុវត្ត ឬធ្វើជាការណែនាំបានឡើយពាក់ព័ន្ធនឹងការបំបែកសំណុំរឿង០០២។ នៅក្នុងករណីនេះ អង្គជំនុំជម្រះសាលាដំបូងអាចស្វែងរកការណែនាំតែពីវិធានផ្ទៃក្នុងតែមួយគត់ ដោយវិធានផ្ទៃក្នុងនេះចែងច្បាស់អំពីវិសាលភាពត្រឹមត្រូវនៃការបំបែកកិច្ចដំណើរការនីតិវិធី។

### ii. វិធាន៧៣*ស្ទួន* របស់តុលាការ ICTY ពុំមែនជាវិធានសមស្របមួយសម្រាប់ណែនាំដល់អង្គជំនុំជម្រះសាលាដំបូងឡើយ

---

[36] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Mladić,* IT-09-92-PT, សំណើរួមរបស់រដ្ឋអាជ្ញាដើម្បីបំបែកដីកាបញ្ជូនរឿងឲ្យទៅជំនុំជម្រះ, កាត់ក្តី ដោយឡែក និងកែប្រែដីកាបញ្ជូនរឿងឲ្យទៅជំនុំជម្រះ ក្នុងសំណុំរឿង Srebinica, ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១១។

[37] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ ៧-១៤។

[38] *ដូចជើងទំព័រខាងលើ*។

១៣. ក្នុងសំណើរបស់ខ្លួន ក.ស.ព បានលើកយកវិធាន ៧៣*ស្ទួន* មកធ្វើជាសំអាង[39] ដោយហេតុថា៖

> វិធានផ្ទៃក្នុង, ច្បាប់ អ.វ.ត.ក ឬ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ពុំបានផ្ដល់ការណែនាំណាមួយអំពីចំណុចដែលត្រូវពិចារណានៅពេលអង្គជំនុំជម្រះសម្រេចថា តើគួរចេញដីកាបំបែកកិច្ចដំណើរការនីតិវិធីដូចម្ដេច ឬថាតើដីកានេះធ្វើឡើងដើម្បីផលប្រយោជន៍នៃយុត្តិធម៌ដែរឬយ៉ាងណា។ ហេតុដូច្នេះ ជាការសមស្របដែលត្រូវពិនិត្យមើលទម្លាប់អនុវត្តន៍អន្តរជាតិ ដោយអនុលោមតាមមាត្រា ៣៣ ថ្មី នៃច្បាប់ អ.វ.ត.ក សម្រាប់ការណែនាំលើបញ្ហាទាំងអស់នេះ[40]។

១៤. ពិតជាការល្អប្រសើរដែលយើងគួរយកទម្លាប់អនុវត្តន៍របស់តុលាការជាតិ និងអន្តរជាតិមកធ្វើការពិចារណា និងយកមកធ្វើជាសំអាងនៅក្នុងពេលមួយសមស្រប។ ប៉ុន្តែវិធាន៧៣*ស្ទួន* នៃតុលាការ ICTY ពុំមែនជាវិធានសមស្របសម្រាប់អង្គជំនុំជម្រះសាលាដំបូងយកមកធ្វើជាការណែនាំបានឡើយពាក់ព័ន្ធនឹងការបំបែកកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក។ វិធាន៧៣*ស្ទួន* របស់តុលាការ ICTY ចែងពីការ "លុបចោលផ្នែកខ្លះ" នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលខុសពីវិធាន ៨៩ *ស្ទួនពីរ* របស់ អ.វ.ត.ក ដែលចែងពីការបំបែកដីកាដំណោះស្រាយជាផ្នែកតូចៗ។ ពេលណាដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានគេលុបចោលជាអចិន្ត្រៃយ៍នូវផ្នែកខ្លះ នោះគឺជាការកាត់ចេញផ្នែកខ្លះនៃដីកា។ អនុលោមតាមវិធាន *៨៩ស្ទួនពីរ* នៅពេលណាដីកាដំណោះស្រាយត្រូវបានអង្គជំនុំជម្រះសាលាដំបូងបែងចែកជាផ្នែក/បំបែកជាផ្នែក ដោយយោងតាមប្រភេទនៃបទចោទ នោះអង្គជំនុំជម្រះសាលាដំបូងអាចបើកសវនាការ២ ឬច្រើនសម្រាប់ដីកាដំណោះស្រាយទាំងមូលតែម្ដង។ អង្គជំនុំជម្រះពុំបានបោះបង់ចោលផ្នែកណាមួយនៃដីកាដំណោះស្រាយឡើយ។ ហេតុដូច្នេះ ការកាត់ចោលផ្នែកខ្លះនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលតុលាការ ICTY បានធ្វើ មានអានុភាពធ្វើឲ្យជនជាប់ចោទទទួលការជំនុំជម្រះពីបទចោទនានា តិចជាងការសម្រេច/ការរំពឹងទុកកន្លងមក។ ផ្ទុយទៅវិញ អ.វ.ត.ក ពុំបានផ្ដល់សិទ្ធិឲ្យអង្គជំនុំជម្រះសាលាដំបូងលុបចោលជាអចិន្ត្រៃយ៍ (ដែលដូច្នេះជាការធ្វើវិសោធនកម្ម) នូវផ្នែកមួយចំនួននៃដីកាដំណោះស្រាយឡើយ។ ការលុបចោលផ្នែកណាមួយនៃដីកាដំណោះស្រាយដែលគ្មានវិការៈ គឺជាការរំលោភទៅនឹងគោលការណ៍ "បញ្ជាក់ការ

---

[39] សំណើ, កថាខណ្ឌ ១៨-៣៥។

[40] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ១៧។

ពិត” ក្នុងប្រព័ន្ធច្បាប់ស៊ីវិល។ អនុលោមតាមវិធាន៨៩*ស្ទួនពីរ* ការបំបែកកិច្ចដំណើរការនីតិវិធី មានន័យយ៉ាងសាមញ្ញថា ជនជាប់ចោទនឹងត្រូវទទួលការជំនុំជម្រះចំពោះបទចោទទាំងអស់ដែល មានរៀបរាប់នៅក្នុងដីកាដំណោះស្រាយ ទោះបីការជំនុំជម្រះមានចំនួនច្រើនដំណាក់កាលក្តី។

១៥. ដោយហេតុថាវិធាន៧៣*ស្ទួន* របស់តុលាការ ICTY លុបចោលផ្នែកខ្លះនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ យើងយល់ថា ដើម្បីជាផលប្រយោជន៍នៃយុត្តិធម៌ ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានលុបចោលផ្នែកខ្លះនេះត្រូវមានកម្រិត “តំណាងសមស្របចំពោះបទល្មើសដែលត្រូវបានចោទប្រកាន់”[41]។ ដោយហេតុថាអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ពុំបានកាត់ចោលផ្នែកខ្លះនៃដីកាដំណោះស្រាយឡើយ ដោយគ្រាន់តែបានបំបែកដីកានេះប៉ុណ្ណោះ វិធាន៨៩*ស្ទួនពីរ* ពុំតម្រូវថា ដើម្បីជាផលប្រយោជន៍នៃយុត្តិធម៌ ដីកាដំណោះស្រាយដែល អ.ជ.ស.ជ បានបំបែកនោះត្រូវតំណាងឲ្យបានត្រឹមត្រូវនូវបទល្មើសដែលត្រូវបានចោទប្រកាន់នោះឡើយ។ ហេតុដូច្នេះ ការដែល ក.ស.ព លើកអំណះអំណាងពុំត្រឹមត្រូវដើម្បីសុំឲ្យអង្គជំនុំជម្រះអនុម័ត និងអនុវត្តនីតិវិធីតុលាការ ICTY នៅ អ.វ.ត.ក ក៏ដូចជាមូលដ្ឋាននានានៃសំណើសុំបំបែកកិច្ចដំណើរការនីតិវិធីរបស់ខ្លួន គឺពុំស្របតាមវិធាន៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុងឡើយ។

### iii. យុត្តិសាស្ត្ររបស់តុលាការ ICTY ពុំសមស្របសម្រាប់ធ្វើជាគំរូដល់អង្គជំនុំជម្រះសាលាដំបូងឡើយ

១៦. ក.ស.ព អះអាងថា អង្គជំនុំជម្រះសាលាដំបូងគួរយកសំណុំរឿង *Karadžić*[42] និង *Milutinović*[43]នៅ

---

[41] វិធាន ៧៣*ស្ទួន* នៃតុលាការ ICTY។

[42] សំណើ, កថាខណ្ឌ ២២, *ដោយលើកយកមកធ្វើជាសំអាងនូវរឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Karadžić, សំណុំរឿងលេខ IT-95-5-T, ដីកាបង្គាប់ទៅអយ្យការតាមវិធាន ៧៣*ស្ទួន* (ឃ), ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៩។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Karadžić, សំណុំរឿងលេខ IT-95-5-T, ប្រតិចារឹកនៃការប្រជុំទៅលើលក្ខន្តិកៈ, ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០៩, ទំព័រ ៤៥១។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Karadžić, សំណុំរឿងលេខ IT -95-5-T, ការដាក់សារណារបស់អយ្យការអនុលោមតាមវិធាន ៧៣ *ស្ទួន* (ឃ), ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Karadžić, សំណុំរឿងលេខ IT-95-5-T, ការដាក់សារណាទីពីររបស់អយ្យការអនុលោមតាមវិធាន ៧៣ *ស្ទួន* (ឃ), ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៩។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Karadžić, សំណុំរឿងលេខ IT -95-5-T, សេចក្តីសម្រេចទៅលើការអនុវត្តវិធាន ៧៣*ស្ទួន* (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ចុះថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៩។

តុលាការ ICTY មកធ្វើជាគំរូណែនាំសម្រាប់សំណុំរឿង០០២។ តុលាការ ICTY ពុំបានបំបែកដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅក្នុងសំណុំរឿងទាំងពីរខាងលើឡើយ ដោយគ្រាន់តែកាត់ចោលផ្នែក ខ្លះប៉ុណ្ណោះ។ នៅក្នុងសំណុំរឿង *Karadžić* ភាគីអយ្យការបានលុបឈ្មោះមន្ត្រីសាលាក្រុងទាំងអស់ចំនួន ៨ រូប ចេញពីការបង្ហាញភស្តុតាង ព្រមទាំងកាត់ចោលនូវហេតុការណ៍ ឬទីតាំងឧក្រិដ្ឋកម្មនីមួយៗពាក់ព័ន្ធនឹងមន្ត្រីសាលាក្រុងដែលនៅសេសសល់, តំបន់ Srebrenic និងការឡោមព័ទ្ធទីក្រុង Sarajevo[44]។ ចំណែកនៅក្នុងសំណុំរឿង *Milutinovič* វិញ ភាគីអយ្យការបានលុបចេញពីដីកាបញ្ជូនរឿងទៅជំនុំជម្រះនូវទីតាំងឧក្រិដ្ឋកម្មចំនួន ៣ កន្លែង ដែលអង្គជំនុំជម្រះសាលាដំបូងយល់ថា "ពាក់ព័ន្ធទៅនឹងការវាយប្រហារតែមួយដែលត្រូវបានចោទប្រកាន់ ឬបណ្តុំនៃហេតុការណ៍មួយខុសៗគ្នា ដែលជាផ្នែកមួយនៃការប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬហេតុការណ៍ឧក្រិដ្ឋកម្មមួយដាច់ដោយឡែកពីគ្នា។ ដូច្នេះទើបអង្គជំនុំជម្រះពុំមានបញ្ហាក្នុងការបំបែកឧក្រិដ្ឋកម្ម ឬហេតុការណ៍ទាំងនោះចេញពីហេតុការណ៍ និងទីតាំងឧក្រិដ្ឋកម្មដទៃទៀតដែលមានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ"[45]។ ជាងនេះទៅទៀត ក្នុងសំណុំរឿង *Milutinovič* អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "ទីតាំងឧក្រិដ្ឋកម្ម និងហេតុការណ៍ផ្សេងៗ ... ឆ្លុះបញ្ចាំងគ្រប់ជ្រុងជ្រោយអំពីវិសាលភាពនៃទង្វើឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ ក៏ដូចជាអំពីជនរងគ្រោះក្នុងចំនួនដ៏ច្រើនសន្ធឹកសន្ធាប់ ហើយតំណាងឲ្យត្រឹមត្រូវអំពីបទល្មើស ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំ

---

[43] សំណើ, កថាខណ្ឌ ២៣, *ដកស្រង់ចេញពី រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Milutinovič *និងអ្នកដទៃទៀត*, សំណុំរឿងលេខ IT-05-87-T, សេចក្តីសម្រេចទៅលើការអនុវត្តវិធាន ៧៣*ស្ទួន*, ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១១, កថាខណ្ឌ ១០-១១។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Milutinovič *និងអ្នកដទៃទៀត*, សំណុំរឿងលេខ IT-05-87-T, សេចក្តីសម្រេចដែលបដិសេធមិនទទួលយកសំណើរបស់អយ្យការសុំចេញការបញ្ជាក់នូវបញ្ហាសម្រាប់បណ្តឹងឧទ្ធរណ៍តាមវិធាន ៧៣*ស្ទួន*, ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៦, កថាខណ្ឌ ១០។

[44] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Karadžić, សំណុំរឿងលេខ IT -95-5-T, ការដាក់សារណារបស់អយ្យការអនុលោមតាមវិធាន ៧៣ *ស្ទួន* (ឃ), ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩។ ជាឧទាហរណ៍ ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានកោសលុបបានដកចេញនូវការសម្លាប់រង្គាលអ្នកទោស កូសូវ៉ូ-អាល់បានី រាប់រយនាក់ ពីពន្ធនាគារនៅ Niš, ប្រទេសស៊ែប។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Milutinovič *និងអ្នកដទៃទៀត*, សំណុំរឿងលេខ IT-05-87-PT, ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានកែប្រែរួមគ្នា (ត្រូវបានកោសលុប), ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៦, កថាខណ្ឌ ៧៥(ញ)។

[45] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Milutinovič *និងអ្នកដទៃទៀត*, សំណុំរឿងលេខ IT-05-87-T, សេចក្តីសម្រេចទៅលើការអនុវត្តវិធាន ៧៣*ស្ទួន*, ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១១, កថាខណ្ឌ ១១។

ជម្រះ"[46]។

១៧. ការអះអាងរបស់ ក.ស.ព ដែលថាអង្គជំនុំជម្រះសាលាដំបូងគួរទទួលយកការណែនាំពីវិធីសាស្ត្ររបស់តុលាការ ICTY ក្នុងសំណុំរឿង *Karadžić* និង *Milutinović* គឺជាការលើកឡើងពុំត្រឹមត្រូវ។ ក្នុងសំណុំរឿង ០០២ នាពេលបច្ចុប្បន្ននេះ អង្គជំនុំជម្រះសាលាដំបូងពុំអាចអនុវត្តតាមវិធីសាស្ត្រខាងលើបានឡើយ។ ហេតុផល**ទីមួយ**គឺថា ក្នុងសំណុំរឿង ០០២ មានជនជាប់ចោទ ៤ រូប ដែលជាសហឧក្រិដ្ឋកម្មរួម, មានគោលនយោបាយចំនួន ៥ ដែលត្រូវបានរងការចោទប្រកាន់, មានទីតាំងឧក្រិដ្ឋកម្ម និងហេតុការណ៍ជាច្រើនដែលត្រូវបានចោទថាជាប់ពាក់ព័ន្ធគ្នា។ ក.ស.ព ពុំបានកំណត់អត្តសញ្ញាណទីតាំងឧក្រិដ្ឋកម្ម ឬហេតុការណ៍ណាមួយដែល**ផ្ទុយស្រឡះ**ពីលក្ខណៈជាសារវ័ន្តឬកម្មវត្ថុនៃសំណុំរឿង និងបញ្ហាក្នុងការបំបែកទីតាំងឧក្រិដ្ឋកម្ម ឬហេតុការណ៍ទាំងនោះចេញពីទីតាំងឧក្រិដ្ឋកម្ម ឬហេតុការណ៍ផ្សេងៗទៀត។ ហេតុផល**ទីពីរ** ការលុបចេញពីដីកាដំណោះស្រាយនូវទីតាំងឧក្រិដ្ឋកម្ម និងហេតុការណ៍នានា គឺមានតម្លៃស្មើទៅនឹងការបដិសេធយុត្តិធម៌សម្រាប់ជនរងគ្រោះនៅតាមទីតាំងឧក្រិដ្ឋកម្ម និងនៅក្នុងហេតុការណ៍ទាំងនោះ។

១៨. ខុសស្រឡះពីសំណុំរឿង *Karadžić* និង *Milutinović* ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីពុំកាត់ចោលផ្នែកខ្លះនៃបទចោទ ឬបោះបង់ចោលបទចោទឡើយ។ អង្គជំនុំជម្រះសាលាដំបូងបានបំបែកដីកាដំណោះស្រាយ ដើម្បីខ្លួនមានលទ្ធភាពជំនុំជម្រះលើបទចោទប្រកាន់នានា ដោយពុំចាំបាច់បំបែកដីកានេះដោយយោងទៅតាមទីតាំងឧក្រិដ្ឋកម្ម និងហេតុការណ៍នានាដែលពុំអាចបំបែកចេញពីគ្នាបានឡើយ។

### ឃ. ការសួរសំណួររបស់ ក.ស.ព ទៅលើភាពត្រឹមត្រូវនៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ដែលថានឹងមានការជំនុំជម្រះលើសំណុំរឿង ០០២ នៅដំណាក់កាលបន្ទាប់ទៀត គឺជាការពុំត្រឹមត្រូវ

១៩. នៅក្នុងសំណើរបស់ខ្លួន ក.ស.ព បានសន្មតថា ក្នុងសំណុំរឿង ០០២ នេះ នឹងមានត្រឹមតែការជំនុំជម្រះដំណាក់កាលដំបូងប៉ុណ្ណោះ ដោយគ្មានការជំនុំជម្រះនៅដំណាក់កាលបន្ទាប់ទៀតឡើយ[47]។ ក.ស.ព ពុំបានទទួលស្គាល់ការចង្អុលបង្ហាញរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងដីកាសម្រេច

---

[46] *ដូចជើងទំព័រខាងលើ*។

[47] សំណើ, កថាខណ្ឌ ៣, ១៥, ២៤, ២៩។

បំបែកកិច្ចដំណើរការនីតិវិធី ដែលថានឹងមានការជំនុំជម្រះនៅដំណាក់កាលបន្ទាប់ទៀតលើសំណុំរឿង ០០២ ទេ។ តាមរយៈការប្រើប្រាស់ពាក្យពេចន៍ដោយប្រយោលនេះ ក.ស.ព មានមន្ទិលទៅលើការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងថា មិនបានដឹងជាមុនអំពីបញ្ហាផ្សេងៗនៅក្នុងការជំនុំជម្រះសំណុំរឿង០០២ជាផ្នែកៗ ហើយសង្ស័យថា អង្គជំនុំជម្រះសាលាដំបូងមិនអាចធ្វើសវនាការដំណាក់កាលទីពីរទៀតបានទេ។ ទាំងអស់នេះអាចជាហេតុផលនាំឲ្យ ក.ស.ព ស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើវិសោធនកម្មលើដីកាដំណោះស្រាយ ដើម្បីកាត់ចោលផ្នែកខ្លះនៃសំណុំរឿង។

### ង. ក.ស.ព ពុំបានបានបង្ហាញ ថា ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ពុំមែនដើម្បីផលប្រយោជន៍នៃយុត្តិធម៌ឡើយ

២០. ក.ស.ព អះអាងថា ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង ពុំបម្រើដល់ "ផលប្រយោជន៍នៃយុត្តិធម៌" ឡើយ[48]។ ក.ស.ព ពុំអើពើទៅនឹងការបញ្ជាក់របស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការបំបែកកិច្ចដំណើរការនីតិវិធីនេះជាផលប្រយោជន៍នៃយុត្តិធម៌។

២១. ច្បាប់ស្ដីពីការបង្កើតឲ្យមាន អ.វ.ត.ក ចែងថា អ.វ.ត.ក ត្រូវធានាឲ្យប្រាកដថាការជំនុំជម្រះ "ប្រព្រឹត្តទៅដោយត្រឹមត្រូវ និងឆាប់រហ័ស"[49]។ វិធាន ២១(៤) ដែលមានចំណងជើងថា "គោលការណ៍ជាសារវ័ន្ត" ចែងថា "ការសម្រេចសេចក្ដីលើការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប"។ អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកថា សិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយឆាប់រហ័ស គឺជាផលប្រយោជន៍នៃយុត្តិធម៌[50]។

២២. ក.ស.ព អះអាងថា " ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីក្នុងទំរង់បច្ចុប្បន្ន ពុំជួយលើកកម្ពស់

---

[48] សំណើ, កថាខណ្ឌ ៣។

[49] ច្បាប់ស្ដីពីការបង្កើតឲ្យមាន អ.វ.ត.ក, មាត្រា ៣៣ ថ្មី។

[50] "ការបំបែកកិច្ចដំណើរការនីតិវិធីនឹងផ្ដល់លទ្ធភាពឲ្យអង្គជំនុំជម្រះអាចចេញសាលក្រមបាន បន្ទាប់ពីការជំនុំជម្រះដោយសង្ខេបនេះការពារបាននូវផលប្រយោជន៍ជាសារវ័ន្តរបស់ជនរងគ្រោះ ក្នុងការទទួលបាននូវយុត្តិធម៌ប្រកបដោយអត្ថន័យ និងទាន់ពេលវេលាព្រមទាំងការពារបាននូវសិទ្ធិទទួលបានការជំនុំជម្រះ ដោយឆាប់រហ័សរបស់ជនជាប់ចោទទាំងអស់នៅក្នុងសំណុំរឿង០០២ទៀតផង"។ ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ៨។

ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវសក្ខីកម្មរបស់សាក្សីនៅក្នុងសវនាការឡើយ...សាក្សី [គួរគប្បី] ផ្តល់សក្ខីកម្មចំពោះរាល់អង្គហេតុទាំងអស់ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលពួកគាត់បានដឹង។ នេះជាមធ្យោបាយតែមួយគត់ដើម្បីបញ្ចៀសការកោះហៅសាក្សីទាំងអស់ជាច្រើនលើក"[51]។ បញ្ហានៅត្រង់ថាតើសំណុំរឿងនេះត្រូវបំបែកតាមការស្នើសុំរបស់ ក.ស.ព ឬតាមដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី។ បញ្ហានេះពុំពាក់ព័ន្ធនឹងវិធីសាស្ត្រនៃការបំបែកសំណុំរឿង ០០២ ឡើយ។

២៣. ក.ស.ព អះអាងថា ការបំបែកកិច្ចដំណើរការនីតិវិធី "ត្រូវធ្វើឡើងដោយធានាថា កំណត់ត្រាប្រវត្តិសាស្ត្រមានភាពត្រឹមត្រូវ ហើយជួយឲ្យជនរងគ្រោះទទួលបានយុត្តិធម៌ និងការផ្សះផ្សាជាតិ"[52]។ ថ្វីបើគោលបំណងរបស់ អ.វ.ត.ក ពុំមែនដើម្បីបញ្ជាក់ការពិតនៃប្រវត្តិសាស្ត្រក្តី[53] ក៏ការបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង បង្កលទ្ធភាពឲ្យកំណត់ការពិតនៃប្រវត្តិសាស្ត្រនៅក្នុងការបញ្ជាក់ការពិតនោះ។

## ច. សំណើសុំផ្សេងទៀតក្នុងការបំបែកកិច្ចដំណើរការនីតិវិធីរបស់ ក.ស.ព នឹងពុំធ្វើឲ្យការជំនុំជម្រះប្រព្រឹត្តទៅបានឆាប់រហ័សឡើយ

២៤. ក.ស.ព អះអាងថា "ការដាក់បញ្ចូលបន្ថែមនូវទីតាំងឧក្រិដ្ឋកម្មទាំងនេះ នឹងពុំអូសបន្លាយការជំនុំជម្រះនៅដំណាក់កាលនេះឡើយ"[54]។ ការអះអាងបែបនេះគ្មានហេតុផលត្រឹមត្រូវអាចទទួលយកបានឡើយ។ ក.ស.ព បានស្នើសុំឲ្យកំណត់ទីតាំងឧក្រិដ្ឋកម្ម, ហេតុការណ៍ និងបទល្មើសមកជំនុំជម្រះឲ្យបានច្រើនជាងនេះ។ បើសិនជាធ្វើបែបនេះ នោះនឹងធ្វើឲ្យមានសាក្សីបន្ថែមចំនួន ៧៣ នាក់មកពីតែ ក.ស.ព (បច្ចុប្បន្ន មានសាក្សីចំនួន ៥៦ នាក់ប៉ុណ្ណោះដែលមានឈ្មោះនៅក្នុងបញ្ជី

---

[51] សំណើ, កថាខណ្ឌ ៣៥។

[52] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ៣៤។

[53] ចំពោះការពិភាក្សាគួរឲ្យចាប់អារម្មណ៍អំពីគោលបំណងដែលទាក់ទងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនានា និងមូលហេតុជាក់លាក់ដែលថាតុលាការទាំងនោះ មិនមានអាណត្តិ "ផ្តល់ការកែតម្រូវលើប្រវត្តិសាស្ត្រសេរីនិយម តាមរយៈការរក្សាទុកកំណត់ត្រានៃការវិនិច្ឆ័យទោសនានាអំពីអ្វីដែលបានកើតឡើងឡើយ..." សូមមើល Patricia M. Wald, *The International Criminal Tribunal for the Former Yugoslavia Comes of Age: Some Observations on Day-to-Day Dilemmas of an International Court*, 5 WASH. U. J. L. & POL'Y, 87, 116 (2001)។

[54] សំណើ, កថាខណ្ឌ ៣៧។

ឈ្មោះសាក្សីរបស់អង្គជំនុំជម្រះសាលាដំបូង)[55] និងឯកសារាប់ពាន់ រួមទាំងឯកសារច្បាប់ជាច្រើនថែមទៀត។ ហេតុដូច្នេះ ការបំបែកកិច្ចដំណើរការនីតិវិធីតាមការស្នើសុំរបស់ ក.ស.ព ប្រហែលពុំអាចធ្វើឲ្យការជំនុំជម្រះប្រព្រឹត្តទៅដោយឆាប់រហ័ស ជាងការបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។ និយាយឲ្យខ្លី ក.ស.ព ពុំបានបង្ហាញឲ្យគេជឿថា ការបំបែកកិច្ចដំណើរការនីតិវិធីដែលខ្លួនបានស្នើឡើង ដែលហួសសមត្ថកិច្ច (*ultra vires*) អាចជួយជាប្រយោជន៍ដល់យុត្តិធម៌ បានច្រើនជាងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង ដែលស្របទៅនឹងពាក្យពេចន៍ និងស្មារតីនៃវិធាន៨៩*ស្ទួនពីរ*។

២៥. ក.ស.ព ចង់ឲ្យមានកំណើននៃទំហំសវនាការដំណាក់កាលដំបូងដោយអង្គហេតុដែលបានវិនិច្ឆ័យរួចមិនត្រូវអនុញ្ញាតឡើយ[56]។ ទោះបីយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា "អង្គជំនុំជម្រះសាលាដំបូង នៅក្នុងដំណាក់កាលណាមួយក៏បាន អាចសម្រេចដាក់បញ្ចូលបន្ថែមនូវផ្នែកផ្សេងទៀតនៃដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២"[57] ដោយ "ការពារនូវផលប្រយោជន៍ជាសារវ័ន្តរបស់ជនរងគ្រោះក្នុងការទទួលបានយុត្តិធម៌ប្រកបដោយអត្ថន័យ និងទាន់ពេលវេលា ព្រមទាំងការពារបាននូវសិទ្ធិទទួលបានការជំនុំជម្រះដោយឆាប់រហ័សរបស់ជនជាប់ចោទទាំងអស់នៅក្នុងសំណុំរឿង០០២ទៀតផង"[58]។ ហេតុដូច្នេះ ទឡ្ហីករណ៍ដែល ក.ស.ព បានលើកឡើងទាក់ទងនឹងភាពចាំបាច់ក្នុងការបំបែកដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយសំអាងថាមិនអាច អនុវត្តអង្គហេតុវិនិច្ឆ័យរួចហើយនោះ គឺជាការផ្លាស់ប្តូរទិសដៅ។

---

[55] "បន្ថែមលើសាក្សីចំនួន ៥៦ នាក់ថែមទៀតនេះ សហព្រះរាជអាជ្ញាធ្លាប់បានស្នើសុំសាក្សីចំនួន ៣២ នាក់ឲ្យមកធ្វើសក្ខីកម្មទាក់ទិននឹងការជម្លៀសប្រជាជនដោយបង្ខំចេញពីក្រុងភ្នំពេញ និងការយកមនុស្សទៅសម្លាប់" *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ៣៩។ "សាក្សីបន្ថែមទាក់ទិននឹងមន្ទីរសន្តិសុខ សហករណ៍ និងការដ្ឋាននានាដែលសហព្រះរាជអាជ្ញាជឿថាអាចនឹងត្រូវបានយកមកបំភ្លឺដែលរួមមាន៖ មន្ទីរ ស២១ (១០នាក់), មន្ទីរសន្តិសុខភូមិភាគឧត្តរ (៦នាក់), ក្រាំងតាចាន់ (៧នាក់), អូរកន្សែង (៥នាក់), សាក្សី ៣ នាក់ដែលបានផ្តល់ព័ត៌មានទូទៅស្តីពីមន្ទីរសន្តិសុខនានា, ព្រលានយន្តហោះកំពង់ឆ្នាំង (៥នាក់), និងសហករណ៍ត្រាំកក់ (៥នាក់)" *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ៤០។

[56] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ២៦-២៧។ សេចក្តីសម្រេចលើសំណើរបស់ អៀង សារី ទាក់ទិននឹងការយកអង្គហេតុពីសំណុំរឿងលេខ ០០១ ដែលបានវិនិច្ឆ័យរួចហើយ និងអង្គហេតុនៃការដឹងឮជាទូទៅមកអនុវត្តក្នុងសំណុំរឿង ០០២, ចុះថ្ងៃទី ៤ ខែមេសា ឆ្នាំ ២០១១, ឯកសារលេខ E69/1, ទំព័រ ២។

[57] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ៦។

[58] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ៨។

## III. មេធាវីការពារក្ដីស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើសវនាការផ្ទាល់មាត់ជាសាធារណៈ

២៦. ប្រសិនបើអង្គជំនុំជម្រះសាលាដំបូង មានបំណងពិចារណាឡើងវិញទៅលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់ខ្លួន មេធាវីការពារក្ដីសូមស្នើសុំដោយគោរពឲ្យអង្គជំនុំជម្រះធ្វើសវនាការផ្ទាល់មាត់ជាសាធារណៈមួយ។ មេធាវីការពារក្ដីសូមស្នើថា នៅមុនពេលចាប់ផ្ដើមសវនាការផ្ទាល់មាត់ ភាគីទាំងអស់ត្រូវជួបប្រជុំជាមួយមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ដើម្បីពិភាក្សាអំពីបែបបទ និងក្របខណ្ឌនៃសវនាការផ្ទាល់មាត់នេះ។ ការធ្វើដូច្នេះនឹងធ្វើឲ្យសវនាការផ្ទាល់មាត់ប្រព្រឹត្តទៅបានដោយផ្ដោតទៅលើប្រធានបទសំខាន់ និងប្រកបដោយប្រសិទ្ធផល។

**អាស្រ័យហេតុនេះ** តាមសំអាងហេតុខាងលើ មេធាវីការពារក្ដីស្នើសុំដោយគោរពឲ្យអង្គជំនុំជម្រះសាលាដំបូងមេត្តា៖

ក. ចាត់ទុកសំណើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញទៅលើដីកាបំបែកកិច្ចដំណើរការនីតិវិធី ថាអាចទទួលយកបាន

ខ. បដិសេធសំណើផ្សេងទៀតរបស់ ក.ស.ព ទាក់ទងនឹងការបំបែកកិច្ចដំណើរការនីតិវិធី

គ. អនុញ្ញាតឲ្យមានសវនាការផ្ទាល់មាត់ជាសាធារណៈ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ខ្លួនត្រូវពិចារណាឡើងវិញទៅលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី។

សូមអង្គជំនុំជម្រះទទួលនូវសេចក្ដីគោរពដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ។

អាង ឧត្ដម Michael G. KARNAVAS

សហមេធាវីរបស់លោក អៀង សារី

ធ្វើនៅភ្នំពេញថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១១